**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ០១.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារ សហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រ េ ច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ដែលមានសមាសភាព ដូចខាងក្រោម :

| | | |
|---|---|---|
| ១- ឯកឧត្តម **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- ឯកឧត្តម **ឆាំន សុរស័ក្តិ** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- ឯកឧត្តម **ត្រាំ សុខា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៤- ឯកឧត្តម **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៥- ឯកឧត្តម **ថោង ខុន** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | សមាជិក |
| ៦- ឯកឧត្តម **ចាន់ តុងអ៊ីវ** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៧- ឯកឧត្តម **នុត ណារ៉ាង** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- ឯកឧត្តម **អ៊ិត ប្រាំង** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល | សមាជិក |
| ៩- ឯកឧត្តម **តាន់ ស៊ុនតូ** | អនុរដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១០- ឯកឧត្តម **ស៊្រុន តារា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១១- ឯកឧត្តម **សួស គង់** | រដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ១២- ឯកឧត្តម **ហ៊ូ តាំងអេង** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៣- លោកជំទាវ **មាស ម៉ារីន** | អនុរដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១៤- ឯកឧត្តម **ហាក់ សិងលី** | អនុរដ្ឋលេខាធិការ ក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៥- ឯកឧត្តម **ហែម សារឹម** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** | សមាជិក |
| ១៦- ឯកឧត្តម **លាង វឌ្ឍនជេន** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៧-លោកជំទាវ **ជូ ប៊ុនអេង** | អគ្គនាយកអភិវឌ្ឍន៍សង្គម ក្រសួងកិច្ចការនារី | សមាជិក |
| ១៧- លោក **សុខ សុភក្រ្ត** | អគ្គនាយករងបច្ចេកទេស ក្រសួងពាណិជ្ជកម្ម | សមាជិក |
| ១៨- លោក **តឹកអ៊ែត សំអេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** | សមាជិក |
| ១៩- តំណាងក្រសួងការពារជាតិ | | សមាជិក |
| ២០- តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | សមាជិក |
| ២១- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | សមាជិក |
| ២២- តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | សមាជិក |
| ២៣- តំណាងក្រសួងសុខាភិបាល | | សមាជិក |
| ២៤- តំណាងក្រសួងកិច្ចការនារី | | សមាជិក |
| ២៥- តំណាងក្រសួងធម្មការ និងសាសនា | | សមាជិក |
| ២៦- តំណាងក្រសួងធនធានទឹក និងឧតុនិយម | | សមាជិក |

២៧- តំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សមាជិក

២៨- តំណាងគណៈកម្មាធិការចំរុះកិច្ចការព្រំដែន សមាជិក

២៩- តំណាងអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន សមាជិក

៣០- ឯកឧត្តម អភិបាលខេត្តរតនៈគីរី សមាជិក

៣១- ឯកឧត្តម អភិបាលខេត្តស្ទឹងត្រែង សមាជិក

៣២- ឯកឧត្តម អភិបាលខេត្តមណ្ឌលគីរី សមាជិក

**មាត្រា ២.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានភារកិច្ច ដូចតទៅ :

- សិក្សា រៀបចំគម្រោង និងកម្មវិធីដែលត្រូវអភិវឌ្ឍដោយឡែក និងអភិវឌ្ឍរួមគ្នា នៅក្នុងតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- ធ្វើជាដៃគូចរចារួមថ្នាក់រដ្ឋមន្ត្រី ជាមួយភាគីឡាវ និងភាគីវៀតណាម ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងរួមគ្នាចរចាជាមួយភាគីផ្តល់ជំនួយទាំងអស់ ដើម្បីរកថវិកាមកអនុវត្តគម្រោង
- គិតគូរអំពីតុល្យភាពនៃការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ត្រីកោណ និងអត្ថប្រយោជន៍ទាំងឡាយដែលប្រជាជននឹងត្រូវទទួលបាន
- សិក្សា និងលើកយោបល់ជូនរាជរដ្ឋាភិបាល អំពីផលប៉ះពាល់នៃការអនុវត្តគម្រោងនានា មកលើបរិស្ថានវប្បធម៌ ប្រពៃណី សាសនា និងទំនៀមទំលាប់នៅក្នុងតំបន់ត្រីកោណ
- រៀបចំកម្មវិធី និងគម្រោងវិនិយោគអាទិភាព លើវិស័យហេដ្ឋារចនាសម្ព័ន្ធ និងកសាងធនធានមនុស្ស
- រៀបចំផែនការសកម្មភាព សម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច អប់រំ បណ្តុះបណ្តាល សុខាភិបាល ទេសចរណ៍ ពង្រឹងសន្តិសុខ សណ្តាប់ធ្នាប់សង្គម និងបង្ក្រាបបទល្មើសឆ្លងដែន នៅក្នុងតំបន់ត្រីកោណ
- ទំនាក់ទំនង និងកៀងគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស សម្រាប់ការសិក្សាស្រាវជ្រាវ និងអនុវត្តកម្មវិធី និងគម្រោងទាំងឡាយ
- ពង្រឹងការឯកភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន មហាអនុតំបន់ទន្លេមេគង្គ និងកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ផ្សេងៗទៀត
- គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-ឡាវ-វៀតណាម ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច

- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម លើរាល់លិខិតស្នាមផ្លូវការ និងមានថវិកាដោយឡែក សម្រាប់ការងាររបស់ខ្លួន ដែលផ្ញើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម ។

សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រធានគណៈកម្មាធិការនេះ មានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងធ្វើការងារ ប្រសិនជាយល់ឃើញថា មានការចាំបាច់ ។

**មាត្រា ៤.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានអនុគណៈកម្មការជំនាញចំនួនបួន ដូចខាងក្រោម :

- អនុគណៈកម្មការការបរទេស និងសន្តិសុខ
- អនុគណៈកម្មការសេដ្ឋកិច្ច
- អនុគណៈកម្មការសង្គមកិច្ច និងបរិស្ថាន
- អនុគណៈកម្មការសម្របសម្រួលថ្នាក់ខេត្ត

ប្រធាន អនុប្រធាន និងសមាជិកអនុគណៈកម្មការជំនាញទាំងបួន ត្រូវតែងតាំងដោយប្រកាសរបស់ប្រធានគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ផ្អែកតាមការចាត់បញ្ជូនពីក្រសួង ស្ថាប័នជំនាញនីមួយៗ ។

**អនុគណៈកម្មការការបរទេស និងសន្តិសុខ** ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី ទីស្តីការគណៈរដ្ឋមន្ត្រី(គណៈកម្មាធិការទទួលបន្ទុកកិច្ចការព្រំដែន) ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន និង អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន ។

**អនុគណៈកម្មការសេដ្ឋកិច្ច** ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងពាណិជ្ជកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ក្រសួងទេសចរណ៍ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

**អនុគណៈកម្មការសង្គមកិច្ច និងបរិស្ថាន** ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងមានសមាជិកមកពី ក្រសួងបរិស្ថាន ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា និងក្រសួងកិច្ចការនារី ។

**អនុគណៈកម្មការសម្របសម្រួលថ្នាក់ខេត្ត** ត្រូវដឹកនាំដោយប្រធានមួយរូប ដែលជាសមាជិកគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និង មានសមាជិកមកពីក្រសួងមហាផ្ទៃ និងតំណាងខេត្តរតនៈគីរី ខេត្តមណ្ឌលគីរី និង ខេត្តស្ទឹងត្រែង ។

អនុគណៈកម្មការទាំងបួននេះ ធ្វើការតាមការណែនាំរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងត្រូវរាយការណ៍ឱ្យទៀតទាត់តាមការកំណត់របស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ។

**មាត្រា ៥.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានលេខាធិការដ្ឋានដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម ។ លេខាធិការដ្ឋាននេះត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពី ប្រធានគណៈកម្មាធិការ ។

**មាត្រា ៦.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានភារកិច្ច ដូចតទៅ :

- ជាសេនាធិការរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម
- សម្របសម្រួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម មានជាអាទិ៍ រៀបចំផែនការការងារ និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម និងអនុគណៈកម្មការជំនាញទាំងបួន
- សម្របសម្រួលការងារជាមួយប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការនានា
- បំពេញការងារដទៃ តាមការណែនាំរបស់របស់ប្រធានគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណកម្ពុជា-ឡាវ-វៀតណាម ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ... ឆ្នាំ ២០០៧

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ០២ . អនក្រ . បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារ សហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## ស ម្រេ ច

**មាត្រា ១.-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ ដែលមានសមាសភាព ដូចខាងក្រោម :

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ចម ប្រសិទ្ធ** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២- | ឯកឧត្តម | **ផាន សួរស័ក្តិ** | រដ្ឋលេខាធិការ ក្រសួងពាណិជ្ជកម្ម | អនុប្រធាន |
| ៣- | ឯកឧត្តម | **ថោង ខុន** | រដ្ឋលេខាធិការ ក្រសួងទេសចរណ៍ | អនុប្រធាន |
| ៤- | ឯកឧត្តម | **ទ្រាំ សុខា** | រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ | សមាជិក |
| ៥- | ឯកឧត្តម | **ត្រាំ អ៊ីវតឹក** | រដ្ឋលេខាធិការ ក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦- | ឯកឧត្តម | **ចំនួ គុងអ៊ីវ** | រដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ | សមាជិក |
| ៧- | ឯកឧត្តម | **នុត ណារ៉ង** | រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ | សមាជិក |
| ៨- | ឯកឧត្តម | **អ៊ិត ប្រាំង** | រដ្ឋលេខាធិការ ក្រសួងឧស្សាហកម្ម រ៉ែនិងថាមពល | សមាជិក |
| ៩- | ឯកឧត្តម | **អេង ហ៊ួត** | រដ្ឋលេខាធិការក្រសួងសុខាភិបាល | សមាជិក |
| ១០- | ឯកឧត្តម | **ខុង សំនួន** | រដ្ឋលេខាធិការ ក្រសួងបរិស្ថាន | សមាជិក |
| ១១- | ឯកឧត្តម | **ស្រ៊ុន តារា** | អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ១២- | ឯកឧត្តម | **ហ៊ូ តាំងអេង** | អនុរដ្ឋលេខាធិការ ក្រសួងផែនការ | សមាជិក |
| ១៣- | ឯកឧត្តម | **ហែម សារឹម** | ទីប្រឹក្សាឯកឧត្តមឧបនាយករដ្ឋមន្ត្រី **ហោ ណាំហុង** | សមាជិក |
| ១៤- | ឯកឧត្តម | **លាភ វណ្ណជេន** | អគ្គលេខាធិការរង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៥- | លោកជំទាវ | **កេត សំអាត** | អគ្គនាយកនៃក្រសួងកិច្ចការនារី | សមាជិក |
| ១៦- | លោក | **តឹករ៉េត សំរេច** | ជំនួយការឯកឧត្តមឧបនាយករដ្ឋមន្ត្រី **សុខ អាន** | សមាជិក |
| ១៧- | តំណាងក្រសួងការពារជាតិ | | | សមាជិក |
| ១៨- | តំណាងក្រសួងអភិវឌ្ឍន៍ជនបទ | | | សមាជិក |
| ១៩- | តំណាងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ | | | សមាជិក |
| ២០- | តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | | | សមាជិក |
| ២១- | តំណាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | | | សមាជិក |
| ២២- | តំណាងក្រសួងធម្មការ និងសាសនា | | | សមាជិក |
| ២៣- | ឯកឧត្តម | អភិបាលខេត្តសៀមរាប | | សមាជិក |
| ២៤- | ឯកឧត្តម | អភិបាលខេត្តឧត្តរមានជ័យ | | សមាជិក |
| ២៥- | ឯកឧត្តម | អភិបាលខេត្តព្រះវិហារ | | សមាជិក |
| ២៦- | ឯកឧត្តម | អភិបាលខេត្តស្ទឹងត្រែង | | សមាជិក |

**មាត្រា ២.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានភារកិច្ច ដូចតទៅ :

- សិក្សា រៀបចំគម្រោង និងកម្មវិធីដែលត្រូវអភិវឌ្ឍដោយឡែក និងអភិវឌ្ឍរួមគ្នា ជាពិសេស លើវិស័យទេសចរណ៍ នៅក្នុងតំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ
- ធ្វើជាដៃគូចរចារួមថ្នាក់រដ្ឋមន្ត្រី ជាមួយភាគីឡាវ និងភាគីថៃ ក្នុងក្របខ័ណ្ឌកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចតំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ និងរួមគ្នាចរចាជាមួយភាគីផ្តល់ជំនួយទាំងអស់ ដើម្បីរកថវិកាមកអនុវត្តគម្រោងដែលបានសិក្សារួច និងដែលនឹងត្រូវសិក្សាសម្រាប់អភិវឌ្ឍន៍នៅពេលខាងមុខ
- គិតគូរអំពីតុល្យភាពនៃការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ត្រីកោណមរកត និងអត្ថប្រយោជន៍ទាំងឡាយ ដែលប្រជាជនកម្ពុជានឹងត្រូវទទួលបាន
- សិក្សា និងលើកយោបល់ជូនរាជរដ្ឋាភិបាល អំពីផលប៉ះពាល់នៃការអនុវត្តគម្រោងនានា មកលើបរិស្ថាន វប្បធម៌ ប្រពៃណី សាសនា និងទំនៀមទំលាប់នៅក្នុងតំបន់ត្រីកោណមរកត
- រៀបចំកម្មវិធី និងគម្រោងវិនិយោគអាទិភាព លើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងកសាងធនធានមនុស្ស
- រៀបចំផែនការសកម្មភាពសម្រាប់អភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច អប់រំ បណ្តុះបណ្តាល សុខាភិបាល ទេសចរណ៍ ពង្រឹងសន្តិសុខសណ្តាប់ធ្នាប់សង្គម និងបង្ក្រាបបទល្មើសឆ្លងដែននៅក្នុង និងឆ្លងកាត់តំបន់ត្រីកោណមរកត
- ទំនាក់ទំនង និងគៀងគរធនធានហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍នានា និងផ្នែកឯកជនទាំងក្នុងប្រទេស និងក្រៅប្រទេស សម្រាប់ការសិក្សាស្រាវជ្រាវ និងអនុវត្តកម្មវិធី និងគម្រោងទាំងឡាយ
- ពង្រឹងការឯកភាពគ្នាក្នុងកិច្ចសហប្រតិបត្តិការក្នុងក្របខ័ណ្ឌអាស៊ាន , មហាអនុតំបន់ទន្លេមេគង្គ , និងកិច្ចសហប្រតិបត្តិការក្នុងអនុតំបន់ផ្សេងៗទៀត គួបផ្សំជាមួយកិច្ចសហប្រតិបត្តិការនៅតំបន់ត្រីកោណមរកត
- គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ ត្រូវរាយការណ៍អំពីលទ្ធផលការងារខាងលើ ជូនរាជរដ្ឋាភិបាល ដើម្បីពិនិត្យ និងសម្រេច
- បំពេញការងារដទៃទៀតតាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល ។

**មាត្រា ៣.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម លើរាល់លិខិតស្នាមផ្លូវការ និងមានថវិកាដោយឡែក សម្រាប់ការងាររបស់ខ្លួន ដែលធ្វើជាមួយនឹងគណនីរបស់ក្រសួងពាណិជ្ជកម្ម ។

សមាជិកគណៈកម្មាធិការនេះ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ។

ប្រធានគណៈកម្មាធិការ នេះមានសិទ្ធិអញ្ជើញមន្ត្រីជាន់ខ្ពស់ និងមន្ត្រីជំនាញនៃក្រសួងពាក់ព័ន្ធឱ្យចូលរួមប្រជុំ និងធ្វើការងារ ប្រសិនជាយល់ឃើញថា មានការចាំបាច់ ។

**មាត្រា ៤.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ អាចបង្កើតអនុគណៈកម្មការជំនាញមួយចំនួនតាមការចាំបាច់ ។

**មាត្រា ៥.-**

គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានលេខាធិការដ្ឋានដែលមានទីស្នាក់ការនៅទីស្តីការក្រសួងពាណិជ្ជកម្ម ។ លេខាធិការដ្ឋាននេះ ត្រូវដឹកនាំដោយលេខាធិការមួយរូប និងជំនួយការមួយចំនួនតាមការចាំបាច់ ។ មន្ត្រីជំនួយការក្នុងលេខាធិការដ្ឋាននេះ ជាមន្ត្រីរបស់ក្រសួងពាណិជ្ជកម្ម ឬជាមន្ត្រីក្របខ័ណ្ឌពីក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដែលទទួលការតែងតាំងពីប្រធានគណៈកម្មាធិការ ។

**មាត្រា ៦.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ មានភារកិច្ច ដូចតទៅ :

- ជាសេនាធិការរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ
- សម្របសម្រួលដំណើរប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ មានជាអាទិ៍ រៀបចំផែនការការងារ និងរៀបចំកិច្ចប្រជុំរបស់គណៈកម្មាធិការ
- សម្របសម្រួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង ស្ថាប័ន ដែលជាសមាជិកគណៈកម្មាធិការជាតិ សម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកតកម្ពុជា-ឡាវ-ថៃ និងសម្របសម្រួលការងារជាមួយអនុគណៈកម្មការជំនាញ
- សម្របសម្រួលការងារជាមួយប្រទេសដៃគូអភិវឌ្ឍន៍ និងអង្គការនានា
- បំពេញការងារដទៃទៀត តាមការណែនាំរបស់របស់ប្រធានគណៈកម្មាធិការជាតិសម្រាប់សម្របសម្រួលការងារសហប្រតិបត្តិការអភិវឌ្ឍន៍តំបន់ត្រីកោណមរកត កម្ពុជា-ឡាវ-ថៃ ។

**មាត្រា ៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៨
- ឯកសារ-កាលប្បវត្តិ

# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:.....០៣.....អនក្រ.បក**

## អនុក្រឹត្យ

## ស្តីពី

## ការបង្កើតតំបន់សេដ្ឋកិច្ចពិសេសកំពត

---

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៣/នស/៩៤ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា និងព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៩ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០០៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលមាត្រា១ នៃអនុក្រឹត្យលេខ ១៤៧ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- បានឃើញអនុក្រឹត្យលេខ ២៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ ស្តីពីការកែសម្រួលលើមាត្រា៤ ចំណុច៤.១

នៃអនុក្រឹត្យលេខ ១៤៨ អនក្រ.បក ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីការបង្កើត និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

- យោងតាមសំណើរបស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

**សម្រេច**

**មាត្រា១.-**

បង្កើត **តំបន់សេដ្ឋកិច្ចពិសេសកំពត** (KAMPOT SEZ) ដែលមានទីតាំងស្ថិតនៅឃុំកោះតូច និងឃុំបឹងទូក ស្រុកកំពត ខេត្តកំពត ។

**មាត្រា២.-**

**តំបន់សេដ្ឋកិច្ចពិសេសកំពត** មានទំហំ ប្រាំបួនរយម្ភៃប្រាំពីរពាន់ មួយរយហាសិប ម៉ែត្រក្រឡា ជាផ្ទៃដីស្ថិតក្នុងផ្នែក A នៃប្លង់ទីតាំងព្រំប្រទល់ភូមិសាស្ត្រក្នុងឧបសម្ព័ន្ធ ដែលមានការឯកភាពពីក្រសួងមានសមត្ថកិច្ច ជាចំណែកភ្ជាប់អនុក្រឹត្យនេះ ។

**មាត្រា៣.-**

ផ្ទៃដីទាំងអស់ដែលស្ថិតក្នុងបរិវេណ **តំបន់សេដ្ឋកិច្ចពិសេសកំពត** ដូចមានកំណត់ក្នុងមាត្រា២ ជាកម្មសិទ្ធិឯកជនស្របច្បាប់របស់ក្រុមហ៊ុន ។

**មាត្រា៤.-**

ការរៀបចំ និងការប្រព្រឹត្តទៅនៃតំបន់សេដ្ឋកិច្ចពិសេសនេះ នឹងស្ថិតក្រោមវិសាលភាពនៃច្បាប់ និងបទប្បញ្ញត្តិនានានៃព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ

និងថាមពល រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អភិបាលខេត្តកំពត និងក្រុមហ៊ុន កំពត ស្ពេសសល អេកូណូមិកហ្សូន ខូអិលធីឌី ត្រូវអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែ មករា ឆ្នាំ២០០៧

នាយករដ្ឋមន្ត្រី

សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រីដើម្បីសូមចុះហត្ថលេខា

អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

អគ្គលេខាធិការ គណៈកម្មាធិការតំបន់សេដ្ឋកិច្ចពិសេសកម្ពុជា

សុខ ចិន្តា

<u>កន្លែងទទួល</u>

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា៥
- ឯកសារ-កាលប្បវត្តិ